**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជននិងកីឡា**
**គម្រោងកែលម្អការអប់រំឧត្តមសិក្សា**(HEIP)
**សាកលវិទ្យាល័យស្វាយរៀង**

# សេចក្តីជូនដំណឹងស្តីពីការជ្រើសរើស
# ជំនួយការគណនេយ្យ និងអ្នកបើកបរ គម្រោង(HEIP)សាកលវិទ្យាល័យស្វាយរៀង

**១-សាវតា** (Background)

គម្រោងកែលម្អការអប់រំកម្រិតឧត្តម (HEIP) IDA Credit No.6221-KH ត្រូវបានអនុម័តដោយធនាគារពិភពលោក នៅថ្ងៃ ទី២៦ ខែមេសាឆ្នាំ២០១៨ ហើយបានចូលជាធរមាននៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ។ សកម្មភាពនៃគម្រោង បានការគាំទ្រមូលនិធិ ពី International Development Association (IDA) ជាកម្ចីក្នុងទំហំទឹកប្រាក់សមមូលនឹង ៩០,០ លានដុល្លារអាមេរិច និង ពីរាជរដ្ឋាភិបាលកម្ពុជាចំនួន ២,៥ លានដុល្លារអាមេរិច ។ គម្រោងនេះគ្រោងអនុវត្តរយៈពេល ៦ ឆ្នាំពោលគឺចាប់ផ្តើមពី ខែកក្កដាឆ្នាំ ២០១៨ និងបញ្ចប់នៅខែមិថុនាឆ្នាំ ២០២៤។ គម្រោងនេះមានគោលបំណង ពង្រឹងប្រព័ន្ធអប់រំឧត្តមសិក្សា និង គាំទ្រដល់ការអភិវឌ្ឍនីតិវិធីនិងវិធានទាំងឡាយសម្រាប់ស្វ័យភាពនៃគ្រឹះស្ថាន ឧត្តមសិក្សា។ អង្គភាពអនុវត្តគម្រោងសាកលវិទ្យាល័យស្វាយរៀងត្រូវការជ្រើសរើស **ជំនួយការគណនេយ្យ ១នាក់ និង អ្នកបើកបរ ១នាក់**។

**២-ភារកិច្ច** (Duties)

**ជំនួយការគណនេយ្យ ជួយគណនេយ្យករ និងមន្ត្រីហិរញ្ញវត្ថុក្នុងការៈ**

- បំពេញលើការកត់ត្រា ការស្រង់ចូលក្នុង System Sage 50
- រក្សាទុកឯកសារ ពាក់ព័ន្ធកិច្ចបញ្ជីការគណនេយ្យ
- ការងារដទៃទៀតដែលពាក់ពន្ធ័នឹងកិច្ចបញ្ជីការគណនេយ្យគម្រោង(HEIP)សាកលវិទ្យាល័យស្វាយរៀង និង
- គាំទ្រការអនុវត្តកិច្ចការគណនេយ្យគម្រោងអោយបានត្រឹមត្រូវមានប្រសិទ្ធិភាព និងជាជំនួយការការគ្រប់គ្រង គម្រោង (HEIP) សាកលវិទ្យាល័យស្វាយរៀង។

**អ្នកបើកបរៈ**

- ដើម្បីផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនសម្រាប់គម្រោង
- សម្អាតរថយន្តដែលខ្លួនទទួលខុសត្រូវជាប្រចាំដើម្បីធានាបាននូវផាសុកភាព អនាម័យ និងសោភ័ណភាព
- តាមដានការថែទាំ និងលើកគម្រោងថែទាំទៅតាមកាលកំណត់និងស្ថានភាពរបស់រថយន្ត ទៅរដ្ឋបាលគម្រោង
- បើកបរដោយប្រុងប្រយ័ត្នគ្រប់ពេលវេលា និងធានាសុវត្ថិភាពដល់អ្នកដំណើរ និងអ្នកប្រើប្រាស់ផ្លូវនិង យានជំនិះដទៃទៀត
- ទៅទទួល ឬ ចែកចាយ ឯកសារ សម្ភារៈ ទៅតាមការចាត់ចែងរបស់រដ្ឋបាលគម្រោង
- ជួយបំពេញភារកិច្ចផ្សេងទៀតនៅក្នុងការិយាល័យទៅតាមការចាត់តាំងនៅពេលមិនបំពេញបេសកកម្ម។

**៣- លក្ខណៈនៃការជ្រើសរើស**(Requirements)

**ជំនួយគណនេយ្យ៖**

១- ចំណេះដឹងនិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ឬ ធនាគារ និង ហិរញ្ញវត្ថុ ឆ្នាំទី២ឡើងទៅ

២- ចេះប្រើប្រាស់ភាសាអង់គ្លេសក្នុងការនិយាយនិងសរសេរ

៣- ចេះប្រើប្រាស់កុំព្យូទ័រសម្រាប់ការងារការិយាល័យ (MS Word, Excel, Powerpoint)

៤- មានបទពិសោធន៍ក្នុងការងារគណនេយ្យ

៥- មានភាពបត់បែន និង ឈ្លាសវៃក្នុងការងារ

**អ្នកបើកបរ៖**

១- មានប័ណ្ណបើកបរមានសុពលភាព ( ប្រភេទ ឃ )

២- មានចំណេះដឹងទាក់ទងនឹងច្បាប់ចរាចរណ៍ និងការពិន័យ

៣- មានបទពិសោធបើកបរយ៉ាងតិច ២ ឆ្នាំនិងមានប្រវត្តិល្អក្នុងការបើកបរ

៤- ភាពបត់បែននិងអាកប្បកិរិយាវិជ្ជមានចំពោះកិច្ចការដែលបានផ្តល់ជូននិងមានឆន្ទៈក្នុងការទទួលយក ការងារសូម្បីតែមុនម៉ោងធ្វើការ ចុងសប្តាហ៍ ឬ អំឡុងពេលឈប់សម្រាក

៥- បញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យត្រូវបានលើកទឹកចិត្ត

**៤- រយៈពេលកិច្ចសន្យា** ( Contract duration )

បេក្ខជនដែលជ្រើសរើសបានត្រូវធ្វើកិច្ចសន្យាអនុវត្តការងារគម្រោងកែលម្អការអប់រំឧត្តមសិក្សា(HEIP)នេះរយៈពេល ១ឆ្នាំ ( ១២ ខែ )ចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាតទៅ ។

**៥. វិធីដាក់ពាក្យសុំ** (How to apply)

បេក្ខជនមានចំណាប់អារម្មណ៍សូមដាក់ពាក្យសុំដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេប ដែលបង្ហាញពីជំនាញការសិក្សា និង បទពិសោធ ព្រមទាំងព័ត៌មានអ្នកដឹងលឺ(referees) យ៉ាងហោចណាស់៣រូប។

សំណុំពាក្យសុំត្រូវផ្ញើទៅអាស័យដ្ឋានខាងក្រោមតាមរយៈអ៊ីម៉ែលឬដោយផ្ទាល់ទៅកាន់

លោកម៉េង វិស្សុត mvissott@sru.edu.kh Tel: 085 775 788.

កាលបរិច្ឆេទឈប់ទទួលពាក្យ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ៥៖00រសៀល

បេក្ខជនដែលជាប់ក្នុងជ្រើសរើសដំបូងប៉ុណ្ណោះដែលនឹងត្រូវទាក់ទងមកសម្ភាសន៍